# ព្រឹត្តិបត្រគតិយុត្តខ្លីៗប្រចាំខែ
# ខែកញ្ញា ឆ្នាំ២០២២
## *ភាគ ៣៣ (១)*

## វិជ្ជាជីវៈនគរបាលយុត្តិធម៌

### ១. តើនគរបាលយុត្តិធម៌ជានរណា?

នគរបាលយុត្តិធម៌ជាជំនួយរបស់តុលាការក្នុងសំនុំរឿងព្រហ្មទណ្ឌ ដែលមានមុខងារពិសេសក្នុងការការពារ និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គមដោយផ្តោតសំខាន់ទៅលើការចូលរួមពង្រឹងផ្នែកយុត្តិធម៌។ អន្តរាគមន៍របស់នគរបាលយុត្តិធម៌អាចកើតមានឡើងក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

ហេតុដូចនេះ អន្តរាគមន៍របស់នគរបាលយុត្តិធម៌មានសារៈសំខាន់ណាស់ក្នុងការឈានទៅដល់ការបង្ក្រាបនូវសកម្មភាពទាំងមូល តាមរយៈការត្រួតពិនិត្យទៅលើការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងកសាងសំណុំរឿង។ បន្ថែមពីនេះ នគរបាលយុត្តិធម៌ជាអ្នកផ្តល់ព័ត៌មានយ៉ាងសំខាន់ជូនតុលាការ ដែលមានអយ្យការ និងចៅក្រមស៊ើបសួរអំពីហេតុដែលខ្លួនបានដឹង។ យោងតាមមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីឋានានុក្រមរបស់នគរបាលយុត្តិធម៌ជាបីគឺ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។

**បច្ចុប្បន្នភាពគតិយុត្តិ**

*ក្រសួងមហាផ្ទៃបានដាក់ចេញសេចក្តីជូនដំណឹង ស្តីពីការផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទៅកាន់ជនអន្តោប្រវេសន៍នៅព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២។ សេចក្តីជូនដំណឹងនេះ គឺអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៥ ន.ស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤។ ការចេញប័ណ្ណនេះក្នុងគោលបំណងបម្រើជីភាពប្រចាំថ្ងៃ ដូចជាការស្នើសុំសេវាវេជ្ជបាល សេវាសាធារណៈ សេវាសុខភាព សេវាធនាគារ ការទិញលក់ចលនវត្ថុ អចលនវត្ថុ ការធ្វើអាជីវកម្ម ការស្នើសុំការងារតាមរោងចក្រ សហគ្រាស និងសកម្មភាពមួយចំនួនទៀត ដែលច្បាប់អនុញ្ញាតសម្រាប់ជនបរទេស។ ទន្ទឹមនឹងនេះ ក្រសួងមហាផ្ទៃក៏បានចេញសេចក្តីណែនាំលេខ ០១៥ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការចេញលិខិតវេជ្ជបាល និងលិខិតអត្រានុកូលដ្ឋានជូនសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍ដោយភ្ជាប់នូវតម្លៃប្រើប្រាស់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដែលក្រសួងបានចេញឱ្យជនបរទេសអន្តោប្រវេសន្តផងដែរ។*

ចំពោះព្រឹត្តិបត្រគតិយុត្តភាគ៣៣ (១) នេះ យើងនឹងធ្វើការបកស្រាយអំពីមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ ហើយសម្រាប់ការបកស្រាយអំពីភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ យើងនឹងធ្វើនៅក្នុងព្រឹត្តិបត្រគតិយុត្តភាគបន្ទាប់។

### ២. តើនគរបាលយុត្តិធម៌មានតួនាទី និងភារកិច្ចអ្វីខ្លះ?

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងបំរើការងារ។ ប៉ុន្តែសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការពង្រីកវិសាលភាពនៃដែនដីប្រទេសទាំងមូល ដោយព្រះរាជអាជ្ញា ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ឬក្នុងករណីបន្ទាន់។ អន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចក្នុងតំបន់នោះ។
តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាបេសកកម្មសំខាន់ៗដូចជា៖

- ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារ បណ្តឹងតវ៉ាពីសាធារណជន
- ពិនិត្យបទល្មើសទាំងឡាយរួមមាន បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ
- ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋម

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

- កាលណាការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរនៅក្នុងលក្ខខណ្ឌ ដែលបានចែងដោយមាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ចាត់ចែងប្រមូលភស្តុតាង ទាំងតាមរយៈការចាប់ផ្តើមស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ឬក្រោមអំណាចដឹកនាំរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេត។
- ធ្វើកំណត់ហេតុ (របាយការណ៍នគរបាល លិខិតលាយលក្ខណ៍អក្សររៀបរាប់អំពីអង្គហេតុនៃរឿងក្តី)
- ក្នុងករណីបទល្មើសជាក់ស្តែង អាចសំសម្រេចឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេល ៤៨ ម៉ោង យ៉ាងយូរ ប្រសិនបើមានការសង្ស័យសមហេតុផល សំរាប់ធ្វើជាមូលដ្ឋានចោទប្រកាន់បាន។
- សុំពន្យាពេលឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេលមិនលើសពី ២៤ ម៉ោង កាលណាលក្ខខណ្ឌទាំង៥ ត្រូវបានបំពេញដែលមានដូចជា (១) ករណីបទឧក្រិដ្ឋធ្ងន់ធ្ងរ (២) មានតម្រុយចង្អុលបង្ហាញច្បាស់លាស់ថាបានប្រព្រឹត្តបទល្មើស (៣) ជាវិធានការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ (៤) ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល (៥) មានចំណារយល់ព្រមពីព្រះរាជអាជ្ញា។

ជាងនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុចំពោះគ្រប់ពាក្យបណ្តឹងទាំងអស់ដែលទទួលបាន ដែលក្នុងកំណត់ហេតុនោះត្រូវរួមបញ្ចូល ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកាលបរិច្ឆេទ ជាពិសេសទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង។

## ៣. តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌?

យោងតាមមាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌មានដូចតទៅ៖

១. មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិច ២ ឆ្នាំ ក្នុងនគរបាលជាតិ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

២. នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំរើការងារយ៉ាងតិចបំផុត ២ ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

៣. អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម៖

- អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់
- ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ , ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ
- ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកនៃនាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន", មន្ទីរប្រឆាំងគ្រឿងញៀន, នាយកដ្ឋាននគរបាលទេសចរណ៍, ស្នងការពិសេសការពារបេតិកភ័ណ្ឌ
- ស្នងការ និងស្នងការរងនគរបាលខេត្ត ក្រុង

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

- ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជាការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល, ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ, ការិយាល័យប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងភេរវកម្ម និងការិយាល័យជនបរទេស
- អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ខណ្ឌ
- ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរណ៍ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរណ៍" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន អនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍
- ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"
- មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ
- មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុងដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ
- មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំ ស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ
- ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ
- ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

ចំពោះមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវបានតែងតាំង ដោយរដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាលយុត្តិធម៌ ឬនៃនាយទាហានកងរាជអាវុធហត្ថ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាព្រឹត្តិបត្រគតិយុត្តខ្លីខាងលើកនេះនឹងចូលរួមជាចំណែកមួយក្នុងការផ្តល់ជូននូវព័ត៌មាន ក៏ដូចជាចំណេះដឹងបន្ថែមដល់សាធារណៈជន និងមិត្តៗអ្នកអានឱ្យបានយល់ដឹងបន្ថែមទៀតអំពីតួនាទី និងភារកិច្ចរបស់នគរបាលយុត្តិធម៌។

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**
**គេហទំព័រ**: www.anna-associates.com
**អ៊ីម៉ែល**: info@anna-associates.com
**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋានការិយាល័យ**: ជាន់ទី៧ អគារលេខ២៣៤ មហាវិថីម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*